# មតិស្វាគមន៍ និងរបាយការណ៍
# ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ
# ក្នុងពិធីប្រកាសតួលេខបណ្តោះអាសន្ននៃ
# ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩

សណ្ឋាគារភ្នំពេញ, ថ្ងៃទី ០៧ ខែសីហា ឆ្នាំ២០១៩

សូមគោរព

- សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិជំរឿន ជាទីគោរពដ៏ខ្ពង់ខ្ពស់
- លោកជំទាវ តំណាងអង្គការមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន UNFPA
- ឯកឧត្តម លោកជំទាវ សមាជិកគណៈកម្មាធិការជាតិជំរឿន
- ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ
- ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
- ឯកឧត្តម លោកជំទាវ លោក ប្រធានមន្ទីរផែនការរាជធានី ខេត្ត
- ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងដៃគូអភិវឌ្ឍន៍ អង្គការជាតិ អន្តរជាតិ

១. ជាបឋម ខ្ញុំសូមគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ ដែលថ្ងៃនេះ សម្តេចបានឆ្លៀតពេលដ៏មមាញឹកផ្តល់កិត្តិយសអញ្ជើញជាអធិបតី នៅក្នុងពិធីប្រកាសតួលេខបណ្តោះអាសន្ននៃជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩។

២. ដូចសម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី បានជ្រាបហើយថា ជំរឿនប្រជាជន គឺជាកិច្ចការដ៏ធំបំផុតមួយនៃដំណើរការប្រតិបត្តិការស្ថិតិនៅក្នុងប្រទេស ដែលជាស៊េរី និងដំណាក់កាលដែលត្រូវអនុវត្តយ៉ាងហ្មត់ចត់ ដើម្បីទទួលបានការរាប់សម្ភាសន៍គ្រប់មនុស្សទាំងអស់នៅទូទាំងប្រទេស នៅក្នុងពេលវេលាជាក់លាក់មួយ ដើម្បីរាប់ចុះបញ្ជីពួកគាត់ បែងចែកតាមចរិតលក្ខណៈផ្សេងៗ។ ជំរឿនផ្ទះសំបែង គឺជាដំណើរការដូចគ្នាជាមួយជំរឿនប្រជាជនដែរ ដែលនឹងទទួលបាននូវចំនួន និងការបែងចែកតាមចរិតលក្ខណៈរបស់លំនៅដ្ឋាន។

៣. បន្ទាប់ពីជំរឿនប្រជាជននៅឆ្នាំ១៩៦២ ដែលពេលនោះប្រជាជនកម្ពុជាមានតែ ៥,៧ លាននាក់នោះ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ត្រូវបានខកខានអស់រយៈពេល ជាង ៣ ទសវត្សរ៍ដោយសារវិបត្តិផ្ទៃក្នុង។ សូមថ្លែងអំណរគុណ ចំពោះអង្គការមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA) ដែលបានជួយឧបត្ថម្ភគាំទ្រទាំងថវិកា និងបច្ចេកទេសដល់ជំរឿន របស់ប្រទេសកម្ពុជាលើកទីមួយឆ្នាំ១៩៩៨ បន្ទាប់ពីអាក់ខាន ៣៦ ឆ្នាំ។ លទ្ធផលជំរឿនប្រជាជន ឆ្នាំ១៩៩៨ បានផ្តល់នូវតួលេខកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យ៉ាងទូលំទូលាយអំពីចរិតលក្ខណៈទិន្នន័យស្ថិតិប្រជាជនកម្ពុជា។ លើសពីនេះទៀត ជំរឿនប្រជាជនឆ្នាំ១៩៩៨ បានធ្វើឲ្យប្រទេសកម្ពុជាបានចូលក្នុងផែនទីជំរឿននៅលើពិភពលោក។ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៨ គឺជាជំរឿនលើកទីពីរ បន្ទាប់ពីការបង្កើតរដ្ឋាភិបាល តាមការបោះឆ្នោតនៅកម្ពុជាឆ្នាំ១៩៩៣។

៤. ខ្ញុំសូមឆ្លៀតឱកាសនេះ សូមថ្លែងអំណរគុណដល់អង្គការមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA) ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន(JICA) រដ្ឋាភិបាលជប៉ុន និងរដ្ឋាភិបាលសាធារណរដ្ឋសហពន្ធ័អាល្លឺម៉ង់ ដែលបានផ្តល់ការឧបត្ថម្ភគាំទ្រទាំងថវិកានិងបច្ចេកទេស ដែលធ្វើឲ្យជំរឿនឆ្នាំ២០០៨ អាចដឹកនាំដំណើរការបានប្រកបដោយជោគជ័យ។ ជំរឿនឆ្នាំ២០០៨ ជាមួយការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០១០ ព្រមទាំងអង្កេតចន្លោះជំរឿនប្រជាជន ឆ្នាំ២០១៣(CIPS) បានចូលរួមចំណែកយ៉ាងធំធេងដែលបានផ្តល់ជារង្វាស់វាស់វែងលក្ខខ័ណ្ឌសេដ្ឋកិច្ចសង្គមកិច្ចរបស់ប្រជាជន។

៥. ប្រទេសកម្ពុជា ជាប្រទេសមួយទើបឆ្លងផុតពីប្រទេសមានចំណូលទាប ឈានចូលជាប្រទេសមានចំណូលមធ្យមកម្រិតទាប។ ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ធ្វើឲ្យប្រទេសមានសុខសន្តិភាព ស្ថេរភាព នយោបាយ និងបានធ្វើការកែទម្រង់គ្រប់វិស័យ។ ដើម្បីណែនាំការអនុវត្តរបៀវារៈគោលនយោបាយសេដ្ឋកិច្ចរបស់រដ្ឋាភិបាល យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ ទី២ ទី៣ ត្រូវបានអនុវត្តដោយរលូន និងប្រកបដោយប្រសិទ្ធភាព។ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ បាន និងកំពុងអនុវត្តដោយផ្តោតជាសំខាន់លើអាទិភាពទាំង ៤ រួមមាន៖ ធនធានមនុស្ស , ផ្លូវ , ទឹក និង ភ្លើង ដែលក្នុងនេះ ធនធានមនុស្ស ជាអាទិភាពទី១។

៦. យោងតាមអនុសាសន៍របស់អង្គការសហប្រជាជាតិ និងយោងតាមច្បាប់ស្តីពីស្ថិតិ រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចដឹកនាំការធ្វើជំរឿនរៀងរាល់ ១០ ឆ្នាំម្តង ដោយចាប់ផ្តើមពីឆ្នាំ១៩៩៨។ ផ្អែកតាមជំរឿន ឆ្នាំ២០០៨ ដែលបានអនុវត្តជាមួយកាលបរិច្ឆេទថ្ងៃទី៣ ខែមីនា ឆ្នាំ២០០៨ នោះ យើងត្រូវអនុវត្តនៅឆ្នាំ២០១៨ ជាក់ស្តែង ១០ឆ្នាំ តាមច្បាប់កំណត់ ក៏ប៉ុន្តែដោយសារមិនមានដៃគូជួយដូចកាល

ជំរឿនមុនៗ យើងត្រូវស្នើថវិកាជាតិ។ ដោយសារឆ្នាំ២០១៨ មានព្រឹត្តិការណ៍សំខាន់ធំមួយគឺការបោះឆ្នោតសកល ដូច្នេះ **សម្តេចនាយករដ្ឋមន្ត្រី** បានសំរេចលើកពេលជំរឿនមកឆ្នាំ២០១៩ ដោយអនុញ្ញាតឲ្យប្រើប្រាស់ថវិកាជាតិទាំងស្រុង។

៧. តួលេខបណ្តោះអាសន្ននៃជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ បានប្រកាសផ្សព្វផ្សាយជូននាថ្ងៃនេះ គឺផ្អែកលើការពិនិត្យពិច័យយ៉ាងហ្មត់ចត់លើតួលេខសង្ខេប ដែលរៀបចំដោយមន្ត្រីសម្ភាសន៍។ តារាងទាំងនោះរួមមាន ចំនួនប្រជាជនកម្ពុជា តាមរាជធានី ខេត្ត តាមភេទ និងតាមចំណាត់ថ្នាក់ទីប្រជុំជន និងជនបទ។ បច្ចុប្បន្ននេះ ការកែច្នៃទិន្នន័យលើតារាងសំណួរជំរឿនបំពេញរួច មានចំនួនប្រមាណជាង ៣,៧ លានគ្រួសារ កំពុងដំណើរការ។ នៅពេលដំណើរការកែច្នៃតារាងសំណួរជំរឿនទាំងអស់រួចរាល់ ហើយលទ្ធផលចុងក្រោយដែលរួមមានតារាងទិន្នន័យសព្វបែបយ៉ាងនឹងមានផ្សព្វផ្សាយជូន។ តារាងស្ថិតិទាំងអស់នេះ សង្ឃឹមថានឹងរួចរាល់នៅពាក់កណ្តាលឆ្នាំក្រោយ (២០២០)។ បន្ទាប់ពីបញ្ចប់ និងផ្សព្វផ្សាយលទ្ធផលចុងក្រោយ នឹងមានការវិភាគទិន្នន័យជំរឿនលម្អិតតាមប្រធានបទសំខាន់ៗ ចំនួន ១៤ ប្រធានបទ ដែលទាក់ទងនឹងសូចនាករប្រជាសាស្ត្រ សង្គម និងផលប៉ះពាល់ចំពោះការអភិវឌ្ឍ។ ក្នុងចំណោមប្រធានបទទាំង១៤ នេះ យើងទទួលបានការសន្យាពីការិយាល័យស្ថិតិសាធារណរដ្ឋប្រជាមានិតចិនជួយវិភាគចំនួន ៤ ប្រធានបទ ហើយអង្គការ UNICEF ក៏អាចជួយវិភាគមួយប្រធានបទផងដែរ។ ដើម្បីបង្កើនការប្រើប្រាស់ទិន្នន័យជំរឿនឲ្យបានទូលំទូលាយ ត្រូវរៀបចំវេបសាយជំរឿន។ សិក្ខាសាលាផ្សព្វផ្សាយ និងការប្រើប្រាស់ទិន្នន័យជំរឿន ត្រូវតែប្រព្រឹត្តទៅទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ទាំង ២៥ រាជធានី ខេត្ត ដើម្បីលើកកម្ពស់ការប្រើប្រាស់ទិន្នន័យជំរឿន។ ខ្ញុំសូមគោរពថ្លែងអំណរគុណ**សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ដែលបានអនុញ្ញាតឲ្យធ្វើការផ្សព្វផ្សាយតួលេខបណ្តោះអាសន្នជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ នាថ្ងៃនេះ ដែលជាតួលេខបណ្តោះអាសន្ន រួមមានចំនួនប្រជាជន និងការវិភាគសង្ខេបអំពីទំហំ និងការបែងចែករបាយប្រជាជនរបស់ប្រទេសកម្ពុជា។

៨. ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ បានប្រព្រឹត្តទៅក្រោមការដឹកនាំរបស់គណៈកម្មាធិការជាតិជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ដែលមាន **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ជាប្រធាន និង ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ ជាអនុប្រធាន ព្រមទាំងសមាជិក រួមមានឯកឧត្តម រដ្ឋលេខាធិការនៃបណ្តាក្រសួងពាក់ព័ន្ធ។ គណៈកម្មាធិការជាតិជំរឿនត្រូវបានជួយគ្រប់ការងារបច្ចេកទេស ដោយគណៈកម្មការបច្ចេកទេសជំរឿន ដែលមានឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ ជាប្រធាន។ គណៈកម្មការឃោសនាជំរឿន មានឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ ជាប្រធាន ទទួល

ខុសត្រូវផ្សព្វផ្សាយ ឃោសនាអំពីជំរឿនជូនសាធារណជន និងស្នើសុំការសហការ។ រាជធានី ខេត្ត នីមួយៗ មាន គណៈកម្មាធិការជំរឿនរាជធានី ខេត្ត ក្រោមការដឹកនាំរបស់ឯកឧត្តមអភិបាលរាជធានី ខេត្ត ទទួលខុសត្រូវការងារជំរឿននៅក្នុងរាជធានី ខេត្តរបស់ខ្លួន។ គណៈកម្មការទាំងអស់នេះ ត្រូវប្រជុំទៀងទាត់តាមពេលវេលាកំណត់ដែលមានចែងក្នុងអនុក្រឹត្យ។

៩. ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ បានដំណើរការអនុវត្តន៍ក្រោមការត្រួតពិនិត្យផ្ទាល់ដោយ អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ និងជំនួយការ ដោយអគ្គនាយករង។ ការិយាល័យជំរឿននៃវិទ្យាស្ថានជាតិស្ថិតិ បានធ្វើការសម្របសម្រួលការងារជំរឿននៅទូទាំងប្រទេស។ ប្រធានមន្ទីរផែនការរាជធានី ខេត្ត ជាមន្ត្រីជំរឿនរាជធានី ខេត្តរបស់ខ្លួន។ មន្ត្រីជំរឿនស្រុក និងមន្ត្រីជំរឿនឃុំ ទទួលបន្ទុកការងារជំរឿនក្នុងស្រុក ឃុំរបស់ខ្លួន។ មន្ត្រីជំរឿនរាជធានី ខេត្ត ត្រូវបានជួយការងារបច្ចេកទេសដោយមន្ត្រីប្រចាំតំបន់ និងមន្ត្រីជំនួយការតំបន់ ដែលជ្រើសចេញពីវិទ្យាស្ថានជាតិស្ថិតិ។

១០. ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ មានវិសាលភាពគ្របដណ្តប់លើគ្រួសារប្រជាជនទូទាំងប្រទេស ចំនួន ៣,៧ លានគ្រួសារ។ គ្រួសារទាំងអស់ត្រូវធ្វើការសម្ភាសន៍ក្នុងអំឡុងពេល ១១ ថ្ងៃ។ ក្រៅពីគ្រួសារដែលរស់នៅក្នុងលំនៅដ្ឋានអចិន្ត្រៃយ៍ធម្មតា គ្រួសារដែលរស់នៅជាលក្ខណៈស្ថាប័ន ដូចជានៅសណ្ឋាគារ ផ្ទះសំណាក់ វត្តអារាម មន្ទីរពេទ្យ ពន្ធនាគារ ជាដើម ក៏ត្រូវបានរាប់សម្ភាសន៍ជំរឿនផងដែរ។ តំបន់ពិសេសដែលបានសម្ភាសន៍ដទៃទៀត រួមមានប្រជាជនគ្មានផ្ទះសំបែង ប្រជាជនឆ្លងកាត់ និងប្រជាជនរស់នៅលើទូក នាយប់ធ្វើជំរឿន ថ្ងៃទី២ ខែមីនា ឆ្នាំ២០១៩។ កងកម្លាំងប្រដាប់អាវុធរស់នៅតាមជំរុំ បន្ទាយ ប៉ុស្តិ៍ប្រចាំការ ក៏ត្រូវបានរាប់ជំរឿនដោយកងកម្លាំងពិសេសផងដែរ។

១១. ការរាប់សម្ភាសន៍ជំរឿន ត្រូវបានអនុវត្តតាមវិធីសាស្ត្រឃើញរាប់ (De-facto) ជាមូលដ្ឋាន ដោយប្រើប្រាស់មន្ត្រីសម្ភាសន៍ ៣៨.៤៤៧ នាក់ និងមន្ត្រីត្រួតពិនិត្យចំនួន ៩.២០០ នាក់ ដែលត្រូវចុះទៅដល់គ្រប់គ្រួសារទាំងអស់ ដើម្បីសម្ភាសន៍រាប់សមាជិកគ្រួសារ ហើយបំពេញចូលក្នុងតារាងសំណួរជំរឿន។ មន្ត្រីជំរឿនទាំងអស់រួមមានមន្ត្រីជំរឿនរាជធានី ខេត្តចំនួន ៧៥ នាក់ គ្រូបង្វឹកតាមរាជធានី ខេត្តចំនួន ៦០០ នាក់ មន្ត្រីជំរឿនស្រុក ក្រុងចំនួន ៤០០ នាក់ មន្ត្រីជំរឿនឃុំ សង្កាត់ចំនួន ១.៧០០ នាក់ ព្រមទាំងមន្ត្រីត្រៀមបម្រុងចំនួន ១.៤០១ នាក់។ មន្ត្រីជំរឿនរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ បានជួយក្នុងការងារបណ្តុះបណ្តាលមន្ត្រីសម្ភាសន៍ជំរឿន និង មន្ត្រីត្រួតពិនិត្យ។ ថ្នាក់ដឹកនាំក្រសួងផែនការទាំងអស់ បានចុះត្រួតពិនិត្យ ការរាប់សម្ភាសន៍ជំរឿន នៅមូលដ្ឋានគ្រប់រាជធានី ខេត្ត និងជួយជំរុញលើកទឹកចិត្តមន្ត្រីសម្ភាសន៍ ឲ្យអនុវត្តការសម្ភាសន៍បានល្អប្រសើ។ លោក

លោកស្រី តំណាងដៃគូអភិវឌ្ឍន៍ ដូចជា UNFPA Sida FAO USAID UNICEF ក៏បានចុះសង្កេតការណ៍ជំរឿនតាមរាជធានី ខេត្តផងដែរ។

១២. កិច្ចការដ៏សំខាន់មួយនៃដំហានដំបូងរបស់ការងារជំរឿន គឺការរៀបចំផែនទីមណ្ឌលជំរឿន។ ការងារនេះបានដំណើរការអនុវត្តតាំងពីខែមិថុនា ឆ្នាំ២០១៧ ដោយមន្ត្រីវិទ្យាស្ថានជាតិស្ថិតិ សហការជាមួយមន្ត្រីមន្ទីរផែនការរាជធានី ខេត្ត ចុះដល់ទីតាំងភូមិទូទាំងប្រទេស ដើម្បីគូសផែនទីមណ្ឌលជំរឿន។ ព្រំប្រទល់ភូមិទាំងអស់ត្រូវបានត្រួតពិនិត្យ និងវាស់វែងទីតាំងរបស់ភូមិនីមួយៗ ដោយប្រើប្រាស់ឧបករណ៍ GPS។ ទូទាំងប្រទេសត្រូវបានចែកជាមណ្ឌលជំរឿនតូចៗ រួមមានជាមធ្យម ១០០ គ្រួសារក្នុងមួយមណ្ឌលជំរឿន ហើយដែលត្រូវបែងចែកជូនមន្ត្រីសម្ភាសន៍ម្នាក់ មួយមណ្ឌលជំរឿន ដើម្បីពួកគាត់អាចសម្ភាសន៍រាប់ជំរឿនប្រជាជននៅក្នុងមណ្ឌលរបស់ខ្លួនបានរួចរាល់នៅក្នុងអំឡុងពេល ១១ ថ្ងៃ។

១៣. មន្ត្រីវិទ្យាស្ថានជាតិស្ថិតិ ទទួលបានការបណ្តុះបណ្តាលយ៉ាងល្អិតល្អន់អំពីប្រតិបត្តិការជំរឿន ដែលធ្លាប់មានតាំងពីជំរឿនឆ្នាំ១៩៩៨ មក។ បន្ទាប់ពីទទួលបានការបណ្តុះបណ្តាលរួចហើយ មន្ត្រីទាំងអស់ត្រូវបានបែងចែកតាមរាជធានី ខេត្ត ធ្វើការបណ្តុះបណ្តាលដល់គ្រូបង្វឹកចំនួន ៦០០ នាក់ ដែលត្រូវបណ្តុះបណ្តាលបន្តដល់មន្ត្រីសម្ភាសន៍ និងមន្ត្រីត្រួតពិនិត្យ សរុបប្រមាណ ៥ម៉ឺននាក់។ មន្ត្រីសម្ភាសន៍ និងមន្ត្រីត្រួតពិនិត្យ ភាគច្រើនរើសចេញពីគ្រូបង្រៀន និងសិស្ស និស្សិត មន្ត្រីនគរបាល នៅតាមមូលដ្ឋានផ្ទាល់។ ពួកគេត្រូវបានទទួលវគ្គបណ្តុះបណ្តាលទាំងទ្រឹស្តី និងការអនុវត្តជាក់ស្តែង មុនពេលចុះប្រតិបត្តិការសម្ភាសន៍ជំរឿនផ្ទាល់នៅមូលដ្ឋាន ។ ការវាយតម្លៃមួយនៃការរាប់សម្ភាសន៍ជំរឿន តាមរយៈការធ្វើអង្កេតក្រោយជំរឿនលើសំណាកគំរូ ១៣០ មណ្ឌលជំរឿន បានឲ្យយើងដឹងបានអំពីអត្រាលំអៀងរាប់សម្ភាសន៍នៃការងារជំរឿន។

**សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី** !

១៤. ប្រជាជនកម្ពុជានាម៉ោងសូន្យថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៩ មាន១៥.២៨៨.៤៨៩ នាក់ ក្នុងនោះប្រុស ៧.៤១៨.៥៧៧ នាក់ និងស្រី ៧.៨៦៩.៩១២ នាក់។ ដង់ស៊ីតេប្រជាជន គឺជាចំនួនប្រជាជនរស់នៅលើផ្ទៃដីមួយគីឡូម៉ែត្រការ៉េ មាន ៨៦ នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ ច្រើនជាងឆ្នាំ ២០០៨ ដែលមានតែ ៧៥ នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ។ ចំនួននេះតិចជាងដង់ស៊ីតេប្រជាជននៅប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ (១២៦ នាក់)។ ដង់ស៊ីតេប្រជាជននៅប្រទេសហ្វីលីពីន (២៨៨) វៀតណាម (២៥៤) ប្រទេសថៃ (១២៧)។ ដង់ស៊ីតេប្រជាជននៅតាមរាជធានី ខេត្ត ប្រែប្រួលពីទាបបំផុត ៦ នាក់ នៅខេត្តមណ្ឌលគិរី រហូតដល់ ៣.១៣៦ នាក់នៅរាជធានីភ្នំពេញ។ បើពិនិត្យតាមតំបន់ភូមិសាស្ត្រ តំបន់វាលទំនាបមានដង់ស៊ីតេប្រជាជនខ្ពស់បំផុត បន្ទាប់មកតំបន់ទន្លេសាប តំបន់ឆ្នេរសមុទ្រ និងតំបន់ខ្ពង់រាប និងភ្នំ។

១៥. តាមតួលេខបណ្តោះអាសន្នបានបង្ហាញថា ក្នុងរយៈពេល ១១ ឆ្នាំ ចន្លោះឆ្នាំ២០០៨ និង ឆ្នាំ២០១៩ ក្នុងអត្រាកំណើនប្រចាំឆ្នាំ ១,២ ភាគរយ អត្រាកំណើនប្រជាជនប្រចាំឆ្នាំបានបន្តធ្លាក់ចុះ អាចដោយសារអត្រានៃលទ្ធភាពបង្កើតកូនធ្លាក់ចុះ និងការធ្វើចំណាកស្រុករបស់ប្រជាជនកម្ពុជាទៅកាន់ប្រទេសផ្សេង ជាពិសេសប្រទេសជិតខាង។ អត្រាកំណើនប្រចាំឆ្នាំខ្ពស់បំផុតត្រឹម ២,២ ភាគរយ ក្នុងមួយឆ្នាំមាននៅតំបន់ខ្ពង់រាប និងភ្នំ ដែលមានខេត្តភាគច្រើននៅភូមិភាគឥសាន្ត ដូចជានៅ ខេត្តព្រះវិហារ (៣,៥%) ក្នុងអត្រាកំណើនប្រចាំឆ្នាំ ខេត្តមណ្ឌលគីរី (៣,៤%) ស្ទឹងត្រែង (៣,២%) ឧត្តរមានជ័យ (៣,១ %) និងរតនគីរី (២,៨%) ដែលជាខេត្តដែលមានលទ្ធភាពបង្កើតកូនខ្ពស់ និង ស្រូបយកការធ្វើចំណាកស្រុកមកពីបណ្តាខេត្តផ្សេងទៀតសម្រាប់ការតាំងលំនៅថ្មី និងជីកសិកម្ម ឱកាសសេដ្ឋកិច្ច និងការអភិវឌ្ឍ។ ដោយឡែករាជធានីភ្នំពេញ និងខេត្តព្រះសីហនុជាខេត្តដែលមានសក្តានុពលចាប់យកឱកាសការងារសេដ្ឋកិច្ច និងការអភិវឌ្ឍខ្ពស់ ជាពិសេសកំណើន វិស័យឧស្សាហកម្ម កាត់ដេរ សំណង់ សណ្ឋាគារ ទេសចរណ៍ និងអប់រំ ដែលទាក់ទាញស្រូបយក ប្រជាជនពីខេត្តផ្សេងៗ ជាពិសេសប្រជាជនវ័យកណ្តាល។ រាជធានីភ្នំពេញ និងខេត្តព្រះសីហនុ មានអត្រាកំណើនមធ្យម ប្រចាំឆ្នាំ តាមលំដាប់រៀង ៣,២% និង ២,៨%។

១៦. អត្រាកំណើនប្រចាំឆ្នាំ ១,២ ភាគរយ បញ្ជាក់ពីភាពស៊ីគ្នាជាមួយគោលនយោបាយ ស្តីពីការប្រើប្រាស់វិធីសាស្ត្រពន្យាកំណើតរបស់ក្រសួងសុខាភិបាល។ គោលនយោបាយវាស់វែង សម្រាប់ជោគជ័យនៃការអនុវត្តវិធីសាស្ត្រពន្យាកំណើត ជាពិសេសការធ្វើសេចក្តីសម្រេចដោយគូស្វាមីភរិយា នូវចំនួនកូន និងចន្លោះពេលដែលត្រូវមានកូន ការកាត់បន្ថយមរណភាពទារក និងកុមារ ដែលជាសញ្ញាបង្ហាញពីជោគជ័យនៃការអនុវត្តសម្រេចបាននូវគោលនយោបាយស្តីពី ការប្រើប្រាស់វិធីសាស្ត្រពន្យាកំណើតរបស់ក្រសួងសុខាភិបាល។

១៧. ប្រជាជនចំណាកស្រុកទៅក្រៅប្រទេស ដើម្បីសិក្សា បណ្តុះបណ្តាល ឬធ្វើការងារបណ្តោះអាសន្ន លើកលែងគ្រួសារអង្គទូតកម្ពុជានៅក្រៅប្រទេស មិនត្រូវបានរាប់បញ្ចូលក្នុងពេលធ្វើជំរឿនដោយវិធីសាស្ត្រឃើញរាប់ទេ (De-facto)។ ទោះបីយ៉ាងណានៅពេលអនាគត កំណើនប្រជាជននៅកម្រិតរាជធានី ខេត្ត ត្រូវធ្វើការត្រួតពិនិត្យ តាមដាន តាមរយៈការធ្វើអង្កេតចន្លោះជំរឿនប្រជាជន នៅរយៈពេល៥ ឆ្នាំខាងមុខ និងការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ដើម្បីបញ្ជាក់ច្បាស់សម្រាប់រៀបចំគោលនយោបាយជាតិប្រជាជន។

១៨. ភ្នំពេញមានប្រជាជនខ្ពស់ជាងគេឈរក្នុងលំដាប់លេខមួយមានចំនួន ២.១២៩.៣៧១ នាក់ (១៣,៩%) ហើយខេត្តកណ្តាលនៅតែឈរក្នុងលំដាប់ទីពីរ ១.១៩៥.៥៤៧ នាក់ (៧,៨%) និងព្រៃវែងឈរក្នុងលំដាប់លេខបី ១.០៥៧.៤២៨ នាក់ (៦,៩%) ចំណែកឯខេត្តកែបនៅតែឈរ

ក្នុងលំដាប់ចុងក្រោយដដែលមានប្រជាជន ៤១.៧៩៨ នាក់ (០,៣%) និងទំហំគ្រួសារមធ្យមនៅកម្ពុជាក្នុងឆ្នាំ២០១៩ មាន ៤,៦ នៅថេរ តាំងពីឆ្នាំ២០០៨។

១៩. ផលធៀបភេទ ឬអត្រាភេទត្រូវកំណត់ដោយចំនួនប្រជាជនបុរស ក្នុងចំណោមស្ត្រី ១០០។ បើផលធៀបភេទលើសពី ១០០ បង្ហាញថាចំនួនបុរសមានលើសពីចំនួនស្ត្រី ផ្ទុយមកវិញបើផលធៀបភេទស្ថិតនៅក្រោម ១០០ បញ្ជាក់ថាចំនួនស្ត្រីមានលើសពីចំនួនបុរស ដែលចង្អុលបង្ហាញចរិតលក្ខណៈសង្គមដ៏សំខាន់មួយ ដើម្បីវាស់វែងពីសមាមាត្រនៃសមធម៌ទូទៅរវាងបុរស និងស្ត្រីនៅក្នុងសង្គម។ ជាទូទៅអត្រាភេទមានក្នុងចន្លោះពី ៩៥ ទៅ ១០៥ លើកលែងតែនៅក្នុង កាលៈទេសៈពិសេស ដូចជាប្រវត្តិសាស្ត្រនៃការបាត់បង់បុរសច្រើនក្នុងសង្គ្រាម ឬការធ្វើចំណាកស្រុក។ បើអត្រាភេទជាតិនៅក្រៅចន្លោះពី ៩០ និង ១០៥ នោះបញ្ហាភេទមានភាពខុសគ្នាខ្លាំងមានឥទ្ធិពលដោយផ្ទាល់ទៅលើការស្វែងរកដៃគូរៀបអាពាហ៍ពិពាហ៍ កម្មវិធីអភិវឌ្ឍន៍ក៏អាចមានផលប៉ះពាល់ខុសគ្នាទៅលើគុណភាពនៃជីវិតរបស់បុរស និងស្ត្រីផងដែរ។

២០. អត្រាភេទកម្ពុជាមាន ៩៤,៣ នេះបើយោងតាមតួលេខបណ្ដោះអាសន្នជំរឿនឆ្នាំ ២០១៩ ចំនួនស្ត្រីមានច្រើនជាងចំនួនបុរសក្នុងចំណោមប្រជាជនកម្ពុជា។ អត្រាភេទកម្ពុជានៅឆ្នាំ ១៩៦២ មានស្មើតែ ១០០ ហើយធ្លាក់ចុះមក ៨៦ ក្នុង ឆ្នាំ១៩៨៦ ដោយសារការបាត់បង់បុរសដោយសារសង្គ្រាម និងការកាប់សម្លាប់ក្នុងរបបខ្មែរក្រហម។ អត្រាភេទកម្ពុជាបានកើនឡើង ៩៥ នៅឆ្នាំ១៩៩៨ និង ៩៤,៥ នៅឆ្នាំ២០០៨ ។ ខេត្តចំនួន ៨ ផលធៀបភេទ ឬអត្រាភេទខ្ពស់លើស ១០០ មានន័យថាចំនួនបុរសច្រើនជាងស្ត្រី គឺខេត្តស្ទឹងត្រែង (១០៨,៧) ឧត្តរមានជ័យ (១០៥,៩) មណ្ឌលគិរី (១០៥,៦) ព្រះសីហនុ (១០២,៤) ប៉ៃលិន (១០២,០) កោះកុង (១០១,៦) ព្រះវិហារ (១០១,៥) និងខេត្តរតនគិរី (១០០,៦)។ រាជធានីភ្នំពេញមានផលធៀបភេទ ឬអត្រាភេទ ៩៥,៣ ហើយខេត្តដែលមានផលធៀបភេទ ឬអត្រាភេទទាបជាងគេ គឺខេត្តបាត់ដំបង អាចដោយសារស្ត្រីពេញវ័យមកធ្វើការនៅតាមរោងចក្រ សហគ្រាស វិស័យផ្សេងៗ ឬចំណាកស្រុកទៅប្រទេសជិតខាងច្រើន។

២១. សម្ដេច ឯកឧត្ដម លោកជំទាវ លោក លោកស្រី នឹងទទួលបានព័ត៌មានលម្អិត នៅក្នុងរបាយការណ៍តួលេខបណ្ដោះអាសន្ននៃជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ ដែលនឹងចែកជូន នាពេលបន្តិចទៀត។

២២. ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណសារជាថ្មី ចំពោះ **សម្ដេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ប្រធានគណៈកម្មាធិការជាតិជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ ដែលបានផ្ដល់កិត្តិយសដ៏ខ្ពង់ខ្ពស់ ចូលរួមជាអធិបតី

ក្នុងពិធីប្រកាសផ្សព្វផ្សាយតួលេខបណ្តោះអាសន្ននៃជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ នាពេលនេះ។ ខ្ញុំសូមគោរពជូនពរ សម្តេច សូមមានសុខភាពល្អ អាយុយឺនយូរ និងសម្រេចបានជោគជ័យគ្រប់ភារកិច្ច។ សូមជូនពរឯកឧត្តម លោកជំទាវ លោកស្រី សូមជួបតែពុទ្ធពរ ៥ ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ។

២៣. ខ្ញុំសង្ឃឹមថា សៀវភៅរបាយការណ៍តួលេខបណ្តោះអាសន្ននៃជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ នេះ នឹងមានសារៈប្រយោជន៍សម្រាប់ជាមូលដ្ឋានក្នុងការប្រើប្រាស់ ដើម្បីការអភិវឌ្ឍប្រទេសកម្ពុជា។

សូមអរគុណ!